# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**គណៈកម្មាធិការគ្រប់គ្រងមូលនិធិ គ.ស.**

លេខ : ១៤ ឯក.គកស

ថ្ងៃពុធ ១៤កើត ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ២០២៣

# សេចក្ដីណែនាំ
## ស្ដីពី
## ការស្ថាបនាស្ថានីយអង់តែនទូរគមនាគមន៍ នៅតាមគោលដៅទេសចរណ៍អាទិភាព និងតំបន់ដាច់ស្រយាល ដោយប្រើមូលនិធិកាតព្វកិច្ចសេវាសកល

ដើម្បីពន្លឿនការស្ថាបនាស្ថានីយអង់តែនទូរគមនាគមន៍ នៅតាមគោលដៅទេសចរណ៍អាទិភាព និងតំបន់ដាច់ស្រយាល ក្នុងគោលដៅបង្កើនវិសាលភាពគ្របដណ្ដប់និងពង្រឹងគុណភាពសេវាទូរគមនាគមន៍ គណៈកម្មាធិការគ្រប់គ្រងមូលនិធិកាតព្វកិច្ចសេវាសកល (**គ.ក.ស.**) សូមណែនាំដល់ប្រតិបត្តិករទូរគមនាគមន៍ ដូចខាងក្រោម៖

១. នៅតាមគោលដៅទេសចរណ៍អាទិភាពនិងតំបន់ដាច់ស្រយាល ត្រូវប្រើប្រាស់ហិរញ្ញប្បទានខ្ពង់ ៤០% នៃមូលនិធិកាតព្វកិច្ចសេវាសកល ហើយត្រូវមានសមត្ថភាពប្រើប្រាស់រួមសម្រាប់ប្រតិបត្តិករទូរសព្ទចល័តយ៉ាងតិចចំនួន ៣ សម្រាប់ការស្ថាបនាផ្នែកអកម្មនៃស្ថានីយអង់តែន (Passive Infrastructure)។

២. ប្រតិបត្តិករទូរសព្ទចល័តអាចស្នើសុំប្រើប្រាស់ហិរញ្ញប្បទានខ្ពង់ ៥០% នៃមូលនិធិកាតព្វកិច្ចសេវាសកល ដើម្បីបំពាក់គ្រឿងសម្ភារៈបរិក្ខារទូរគមនាគមន៍ផ្នែកសកម្មនៃស្ថានីយអង់តែនថ្មី (Active Infrastructure)។

៣. គ្រឿងសម្ភារៈបរិក្ខារទូរគមនាគមន៍ផ្នែកសកម្មនៃស្ថានីយអង់តែនថ្មីដែលត្រូវបំពាក់ដោយប្រតិបត្តិករទូរសព្ទចល័ត ត្រូវគោរពតាមស្តង់ដាបច្ចេកទេស និងអនុលោមតាមគោលការណ៍យថាប្រភេទជាធរមាន។

៤. **គ.ក.ស.** នឹងធ្វើការជ្រើសរើសប្រតិបត្តិករបង្គោលអង់តែនទូរគមនាគមន៍ដែលមានគុណវុឌ្ឍិ ដើម្បីសាងសង់និងថែទាំផ្នែកអកម្មនៃស្ថានីយអង់តែន។

៥. ប្រតិបត្តិករទូរសព្ទចល័តដែលត្រូវបំពាក់គ្រឿងសម្ភារៈបរិក្ខារទូរគមនាគមន៍ផ្នែកសកម្មនៃស្ថានីយអង់តែនថ្មី ត្រូវទទួលបន្ទុកលើប្រតិបត្តិការប្រចាំថ្ងៃក្នុងការផ្ដល់សេវាជូនអ្នកប្រើប្រាស់។ ដើម្បីសម្រាលបន្ទុកចំណាយប្រតិបត្តិការ **គ.ក.ស.** នឹងជួយរ៉ាប់រងចំណាយលើការជួល ដោយតម្រូវឱ្យប្រតិបត្តិករទូរសព្ទចល័តបង់ថ្លៃបដិភាគប្រើប្រាស់និងថែទាំផ្នែកអកម្មនៃស្ថានីយអង់តែន ត្រឹម ១០០ ដុល្លារអាមេរិកក្នុងមួយខែប៉ុណ្ណោះ។ នៅពេលដែលទីតាំងស្ថានីយអង់តែននោះ មានចំនួននៃការប្រើប្រាស់កើនដល់ជាមធ្យម ៥០០ អ្នកប្រើប្រាស់ (Subscribers) ក្នុងមួយខែ ថ្លៃប្រើប្រាស់និងថែទាំផ្នែកអកម្មនៃស្ថានីយអង់តែន នឹងត្រូវគិតតាមតម្លៃទីផ្សារជាក់ស្ដែង។

អាស្រ័យហេតុនេះ សូម ប្រតិបត្តិករទូរគមនាគមន៍ ចូលរួមអនុវត្តប្រកបដោយការទទួលខុសត្រូវខ្ពស់។

**កន្លែងទទួល ៖**
- អនុប្រធាន និងសមាជិក **គ.ក.ស.**
  "ដើម្បីជូនជ្រាប"
- និយ័តករទូរគមនាគមន៍កម្ពុជា
- សេនាធិការដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ និងសេនាធិការដ្ឋានបច្ចេកទេស នៃ **គ.ក.ស.**
- ប្រតិបត្តិករទូរគមនាគមន៍
  "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ

អគារលេខ ១៣ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ 120210
123 023 724 810
www.usof.gov.kh

KINGDOM OF CAMBODIA
NATION RELIGION KING

THE MANAGEMENT COMMITTEE
OF THE USO FUND

*[Unofficial Translation]*

№ : ..........................................

Phnom Penh, 31 May 2023

**Instruction**
**On**
**The Construction of Base Transceiver Stations at Priority Tourist Destinations and Remote Areas, Funded by the Universal Service Obligation Fund**

In an effort to expedite the construction of base transceiver stations at priority tourist destinations and remote areas and to expand the coverage and strengthen the quality of telecoms services, the Management Committee of the Universal Service Obligation Fund (the Management Committee) wishes to instruct all telecoms operators the following:

1. The installation of the passive infrastructure of the BTS at priority tourist destinations and remote areas must be financed under the 40 percent allocation of the USO Fund; the passive infrastructure must be made available for sharing for at least three mobile network operators.
2. Mobile network operators wishing to install the active infrastructure of the BTS may request financing under the 50 percent allocation of the USO Fund.
3. The active infrastructure to be installed at new BTS must follow the technical standards and comply with type approval conformity.
4. The Management Committee will select the qualified telecoms tower operator to build and maintain the passive infrastructure of the BTS.
5. Mobile network operators in charge of installing the active infrastructure of the new BTS are responsible for the daily operations in service provision. To reduce the operating costs, the Management Committee will help cover the rental expense, with the MNOs having to pay only $100 per month for using and maintaining the passive infrastructure of the BTS. When the BTS has an average of 500 subscribers per month, the rental and maintenance fees of the passive infrastructure of the BTS will be leased at the effective market rates.

In this regard, please all telecoms operators implement responsibly.

Recipients:
- Deputy directors and members of the Management Committee
“Be informed”
- Telecommunication Regulator of Cambodia
- Administrative and Financial Secretariats of the Management Committee
- Telecoms Operators
“To Implement”
- Archives